ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 2

## សន្និធិ
## Inventories

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ **"ឈ្នះ-ឈ្នះ"** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣"**, **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨"**, **"យុទ្ធសាស្ត្រត្រីកោណ"**, **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០"** និង **"យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨"** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី **"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៙

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង“ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្ដើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្ដីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ”នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង *“ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**វី តាយី**

## គោលដៅ

១ គោលដៅនៃស្តង់ដានេះពិពណ៌នាអំពីកំណត់ត្រាគណនេយ្យចំពោះ សន្និធិ ។ បញ្ហាដំបូងក្នុងការកត់ត្រាគណនេយ្យចំពោះសន្និធិ គឺជាចំនួនទឹកប្រាក់ថ្លៃដើមដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្ម និងត្រូវរក្សាទុករហូតដល់ចំណូលពាក់ព័ន្ធត្រូវបានទទួលស្គាល់។ ស្តង់ដានេះ ចែងអំពីគោលការណ៍ណែនាំ ចំពោះការកំណត់ថ្លៃដើម និងការទទួលស្គាល់បន្តបន្ទាប់ថាជាចំណាយ រួមបញ្ចូលទាំងការកត់ត្រាចូលជាតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន។ វាក៏ចែងអំពីគោលការណ៍ណែនាំស្តីពីរូបមន្តថ្លៃដើម ដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់តម្លៃចំពោះសន្និធិ ។

## វិសាលភាព

២ ស្តង់ដានេះ អនុវត្តចំពោះគ្រប់សន្និធិទាំងអស់ លើកលែងតែ÷

(ក) ការងារដែលកំពុងដំណើរការដែលកើតឡើងតាមកិច្ចសន្យាសាងសង់ រួមបញ្ចូលទាំងកិច្ចសន្យាលើសេវាពាក់ព័ន្ធផ្ទាល់ដ៏ទៃទៀត (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិលេខ១១ ស្តីពី *កិច្ចសន្យាសាងសង់*)

(ខ) ឧបករណ៍ហិរញ្ញវត្ថុ (សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣២ ស្តីពី *ឧបករណ៍ហិរញ្ញវត្ថុៈ ការបង្ហាញ* និង ស.រ.ហ.អ លេខ ៩ ស្តីពី *ឧបករណ៍ហិរញ្ញវត្ថុ)* និង

(គ) ទ្រព្យសកម្មជីវសាស្ត្រដែលទាក់ទិនទៅនឹងសកម្មភាពផ្នែកកសិកម្ម និងកសិផលនាពេលប្រមូលផល (សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៤១ ស្តីពី*កសិកម្ម*)។

៣ ស្តង់ដានេះ មិនអនុវត្តចំពោះការវាស់វែងសន្និធិដែលកាន់កាប់ដោយ÷

(ក) ផលិតករនៃកសិផលនិងផលពីព្រៃឈើ កសិផលក្រោយពេលប្រមូលផល និងរ៉ែនិងផលិតផលរ៉ែ ករណីវាទាំងនោះត្រូវបានវាស់វែងតាមតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន ស្របតាមការអនុវត្តដ៏ល្អដែលធ្លាប់បានធ្វើឡើងក្នុងវិស័យនោះ។ នៅពេលដែលសន្និធិទាំងនោះត្រូវបានវាស់វែងតាម តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន ការប្រែប្រួលលើតម្លៃរបស់វា ត្រូវបានទទួលស្គាល់ជាចំណេញ-ខាតនៅក្នុងការិយបរិច្ឆេទដែលមានការប្រែប្រួល។

(ខ) ពាណិជ្ជករជាឈ្មួញកណ្តាល ដែលវាស់វែង សន្និធិរបស់ពួកគេតាមតម្លៃទីផ្សារ ដកឱ្យថ្លៃដើមលក់ ហើយការប្រែប្រួលលើតម្លៃទីផ្សារដកឱ្យថ្លៃដើមលក់ ត្រូវបានទទួលស្គាល់ជា ចំណេញខាតក្នុងការិយបរិច្ឆេទដែលមានការប្រែប្រួល ។

៤ សន្និធិដែលសំដៅដល់នៅក្នុងកថាខ័ណ្ឌ ៣(ក) ត្រូវបានវាស់វែងតាមតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន តាមដំណាក់កាលជាក់ស្តែង នៃផលិតកម្ម។ ឧទាហរណ៍ករណីខាងលើវាកើតឡើងនៅពេលដែលដំណាំកសិកម្មត្រូវបានប្រមូល ឬរ៉ែត្រូវបានទាញយកផល ហើយការលក់ត្រូវបានធានា ដោយកិច្ចសន្យាដែលបានបង្កើតជាមុនមួយ ឬតាមការធានារបស់រដ្ឋាភិបាល ឬនៅពេលដែលទីផ្សារសកម្មកើតមាន ព្រមទាំងមានហានិភ័យតិចតួច ដែល

នាំឱ្យមិនអាចលក់បាន ។ សន្និធិទាំងនេះ ត្រូវបានដកចេញពីស្តង់ដានេះ តែចំពោះលក្ខខណ្ឌនៃការវាស់វែងប៉ុណ្ណោះ ។

៥ ពាណិជ្ជករជាឈ្មួញកណ្តាល គឺជាពាណិជ្ជករដែលលក់ឬទិញទំនិញសម្រាប់អ្នកដទៃ ឬដើម្បីគណនីផ្ទាល់ខ្លួន ។ សន្និធិដែលបានលើកឡើងនៅក្នុងកថាខ័ណ្ឌ ៣(ខ) សំខាន់ត្រូវបានទិញ ក្នុងគោលបំណងលក់វិញនាពេលអនាគត និងប្រមូលនូវប្រាក់ចំណេញពីការឡើងចុះថ្លៃ ឬពីគម្លាតថ្លៃរបស់ពាណិជ្ជករជាឈ្មួញកណ្តាលនោះ ។ នៅពេលដែលសន្និធិទាំងនេះត្រូវបានវាស់វែងតាមតម្លៃទីផ្សារ ដកឱ្យថ្លៃដើមលក់ ហើយសន្និធិទាំងនោះត្រូវដកចេញតែពីការតម្រូវសម្រាប់ការវាស់វែងតាមស្តង់ដានេះប៉ុណ្ណោះ ។

## និយមន័យ

៦ វាក្យស័ព្ទដែលប្រើប្រាស់ក្នុងស្តង់ដានេះ មានអត្ថន័យដូចខាងក្រោមៈ

***សន្និធិ*** គឺជាទ្រព្យសកម្មដែលៈ

(ក) ទុកសម្រាប់លក់នៅក្នុងសកម្មភាពអាជីវកម្មជាធម្មតារបស់អង្គភាព

(ខ) កំពុងស្ថិតនៅក្នុងដំណើរការផលិតកម្មសម្រាប់យកទៅលក់ ឬ

(គ) ស្ថិតក្នុងទម្រង់ជាវត្ថុធាតុដើម ឬគ្រឿងផ្គត់ផ្គង់ដែលត្រូវបានប្រើប្រាស់ក្នុងចង្វាក់ផលិតកម្ម ឬនៅក្នុងការផ្តល់សេវាកម្ម ។

***តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន*** គឺជាតម្លៃលក់ដែលបានប៉ាន់ស្មាននៅក្នុងដំណើរការជាធម្មតានៃអាជីវកម្ម ដកឱ្យថ្លៃដើមប៉ាន់ស្មានចុងក្រោយ និងថ្លៃដើមប៉ាន់ស្មានចាំបាច់នានាដើម្បីលក់ ។

*តម្លៃទីផ្សារ* គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មមួយអាចដោះដូរជាមួយ បាន ឬបំណុលត្រូវបានទូទាត់សង ជាមួយភាគីពាក់ព័ន្ធនៅក្នុងសកម្មភាព អាជីវកម្ម ។

៧ តម្លៃសុទ្ធដែលគួរទុកចិត្តបាន សំដៅដល់ចំនួនទឹកប្រាក់សុទ្ធដែលអង្គភាព រំពឹងថានឹងប្រមូលបានពីការលក់សន្និធិដែលមាននៅក្នុងសកម្មភាពអាជីវ កម្មធម្មតា (ជាប្រចាំ) ។ តម្លៃទីផ្សារបង្ហាញអំពីចំនួនទឹកប្រាក់ដែលសន្និធិ ដដែលនោះអាចដោះដូរជាមួយអ្នកទិញដែលមានបំណងទិញ និងដែល បានស្គាល់ជាមួយនឹងអ្នកលក់នៅក្នុងទីផ្សារមួយ ។ តម្លៃសុទ្ធ ដែលគួរទុក ចិត្តបាន គឺជាតម្លៃជាក់លាក់របស់អង្គភាព ហើយតម្លៃទីផ្សារមិនមែនជា តម្លៃជាក់លាក់ របស់អង្គភាពទេ ។ តម្លៃសុទ្ធ ដែលគួរទុកចិត្តបានសម្រាប់ សន្និធិ អាចមិនស្មើជាមួយនឹងតម្លៃទីផ្សារ ដកឱ្យថ្លៃដើមលក់ ។

៨ សន្និធិរួមមានទាំង ទំនិញដែលបានទិញ និងរក្សាទុកសម្រាប់លក់វិញ ឧទាហរណ៍ ដូចជាម៉ាស៊ីនដែលបានទិញដោយអ្នកលក់រាយនិងទុកសម្រាប់ លក់ ឬដីនិងទ្រព្យសម្បត្តិដទៃទៀតដែលទុកសម្រាប់លក់វិញ ។ សន្និធិក៏ រួមបញ្ចូលផងដែរនូវផលិផលសម្រេចដែលបានផលិត ឬ ការងារដែល កំពុងដំណើរការនៅក្នុងផលិតកម្ម ដោយអង្គភាពមួយ និងរួមបញ្ចូលទាំង វត្ថុធាតុដើម និងឧបករណ៍ប្រើប្រាស់ដែលរង់ចាំប្រើប្រាស់នៅក្នុងដំណើរ ការផលិតកម្ម ។ ក្នុងករណីផ្តល់សេវាកម្ម សន្និធិរួមមានថ្លៃដើមសេវាដូច ដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌទី ១៩ ដែលអង្គភាពមិនទាន់បាន ទទួលស្គាល់ជាចំណូលពាក់ព័ន្ធ (សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិ លេខ ១៨ ស្តីពី *ចំណូល* ។

៩ សន្និធិ ត្រូវបានវាស់វែងតាមតម្លៃទាបបំផុត និងតាមតម្លៃសុទ្ធដែលគួរទុកចិត្តបាន ។

## ថ្លៃដើមរបស់សន្និធិ

**១០ ថ្លៃដើមរបស់សន្និធិ ត្រូវមានសមាសធាតុនៃគ្រប់ថ្លៃដើមទិញទាំងអស់ ថ្លៃដើមបំលែង និងថ្លៃដើមដទៃទៀត ដែលបានកើតឡើងក្នុងការនាំសន្និធិទៅដល់ទីកន្លែងរបស់វានិងតាមលក្ខខ័ណ្ឌសមប្រកប ។**

## ថ្លៃដើមទិញ

១១ ថ្លៃដើមទិញសន្និធិ រួមមាន ថ្លៃទិញ ពន្ធនាំចូល និងពន្ធផ្សេងទៀត (ក្រៅពីពន្ធដែលអង្គភាពអាចទារវិញបានពីអាជ្ញាធរពន្ធ) និងការដឹកជញ្ជូន ការរត់ការ ព្រមទាំងថ្លៃដើមដទៃទៀត ដែលអាចបញ្ចូលដោយផ្ទាល់ជាមួយការទិញផលិតផលសម្រេច វត្ថុធាតុដើម និងសេវាកម្ម ។ អប្បហារពាណិជ្ជ-កម្ម ប្រាក់ដែលបង្វិលសង និងធាតុប្រហាក់ប្រហែលដទៃទៀត ត្រូវបានកាត់ចេញក្នុងការកំណត់អំពីថ្លៃដើមទិញ ។

## ថ្លៃដើមបំលែង

១២ ថ្លៃដើមបំលែងនៃសន្និធិ រួមមានថ្លៃដើមដែលទាក់ទងដោយផ្ទាល់ជាមួយនឹងឯកតាផលិតកម្ម ដូចជាថ្លៃពលកម្មផ្ទាល់ ។ វារួមបញ្ចូលផងដែរនូវការធ្វើវិភាជជាប្រព័ន្ធនៃចំណាយផលិតកម្មថេរនិងប្រែប្រួល ដែលបាន

កើតឡើងនៅពេលបំលែងវត្ថុធាតុដើមទៅជាផលិតផលសម្រេច។ ចំណាយផលិតកម្មថេរ គឺជាថ្លៃដើមមិនផ្ទាល់នៃផលិតកម្មដែលមានជានិច្ចកាល ដោយមិនគិតពីទំហំផលិតកម្ម ដូចជាការរំលោះនិងការថែទាំអគារ រោង-ចក្រ និងសម្ភារៈ ព្រមទាំងថ្លៃដើមនៃការគ្រប់គ្រងនិងរដ្ឋបាលរោងចក្រ ។ ចំណាយផលិតកម្មប្រែប្រួល គឺជាចំណាយថ្លៃដើមផលិតកម្មមិនផ្ទាល់ ដែលប្រែប្រួលដោយផ្ទាល់ ឬស្ទើតែផ្ទាល់ជាមួយទំហំផលិតកម្ម ដូចជាវត្ថុធាតុដើមមិនផ្ទាល់ និងពលកម្មមិនផ្ទាល់ជាដើម ។

១៣ ការធ្វើវិភាជចំណាយផលិតកម្មថេរ ទៅជាថ្លៃដើមបំលែង គឺត្រូវផ្អែកលើមូលដ្ឋាននៃសមត្ថភាពជាធម្មតានៃសម្ភារៈផលិតកម្ម។ សមត្ថភាពធម្មតា គឺជាផលិតកម្ម ដែលបានរំពឹងទុកថានឹងសម្រេចបានជាមធ្យមក្នុងការិយ-បរិច្ឆេទ ឬរដូវកាលក្រោមលក្ខខណ្ឌធម្មតា ដោយត្រូវគិតអំពីការបាត់បង់សមត្ថភាពដែលបណ្តាលមកពីការថែទាំដែលបានគ្រោង ។ កម្រិតជាក់ស្តែងនៃផលិតកម្ម អាចត្រូវបានប្រើប្រាស់ ប្រសិនបើការផលិតនោះ ខិតជិតសមត្ថភាពធម្មតា។ ចំនួនទឹកប្រាក់នៃចំណាយថេរដែលផ្តល់ដល់ឯកតាផលិតកម្មនីមួយៗ មិនកើនឡើងដោយសារតែការផលិតទាប ឬរោងចក្រមិនដំណើរការនោះទេ។ ចំណាយដែលបានធ្វើ ត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលចំនាយនោះបានកើតឡើង ។ ក្នុងការិយ-បរិច្ឆេទដែលការផលិតមានការកើនឡើងមិនធម្មតា ចំនួនទឹកប្រាក់ចំណាយថេរដែលផ្តល់ដល់ឯកតាផលិតកម្មនីមួយៗ ត្រូវថយចុះ ដូចនេះ សន្និធិមិនត្រូវវាស់វែងថ្លៃដើមទាំងនោះទេ ។ ចំណាយផលិតកម្មដែលប្រែប្រួលត្រូវបានផ្តល់ដល់ឯកតាផលិតកម្មនីមួយៗ ដោយផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់ជាក់ស្តែងនៃមធ្យោបាយផលិតកម្ម ។

១៤ ដំណើរការផលិតកម្ម អាចនាំឱ្យមានផលិតផលដែលត្រូវផលិតក្នុងពេលតែមួយលើសពីមួយ ។ ឧទាហរណ៍ ដូចជាករណីនៅពេលដែលផលិតផលរណោបត្រូវបានផលិតឡើង ឬនៅពេលដែលមានផលិតផលចម្បង និងអនុផល ។ នៅពេលដែលថ្លៃដើមបំលែងនៃផលិតផលនីមួយៗ មិនអាចត្រូវ បានកំណត់ដាច់ដោយឡែកពីគ្នាបាន ថ្លៃដើមទាំងនោះ ត្រូវបានផ្តល់រវាង ផលិតផលនានាដោយឈរលើមូលដ្ឋានសមហេតុផលនិងមានសង្គតិភាព ។ ឧទាហរណ៍ ការផ្តល់នូវថ្លៃដើម អាចផ្អែកលើមូលដ្ឋាននៃតម្លៃលក់ពាក់ព័ន្ធ នៃផលិតផលនីមួយៗ ទាំងនៅក្នុងដំណាក់កាលចង្វាក់ផលិតកម្ម ដែល ផលិតផល អាចកំណត់ដាច់ដោយឡែកពីគ្នា និងទាំងនាពេលបញ្ចប់ការ ផលិត ។ យោលលើធម្មជាតិនៃអនុផលភាគច្រើនវាមានលក្ខណៈមិន សំខាន់ ។ ករណីនេះ អនុផលជារឿយៗត្រូវបានវាស់វែងតាម តម្លៃសុទ្ធ ដែលគួរឱ្យទុកចិត្តបាន ហើយតម្លៃនេះ ត្រូវបានកាត់ចេញពី ថ្លៃដើមនៃ ផលិតផលចម្បង។ ជាលទ្ធផល តម្លៃពិតគណនេយ្យរបស់ផលិតផលចម្បង មិនខុសគ្នាឆ្ងាយពីថ្លៃដើមរបស់វា ។

## ថ្លៃដើមដទៃទៀត

១៥ ថ្លៃដើមដទៃទៀត ត្រូវបានបញ្ចូលនៅក្នុងថ្លៃដើមនៃសន្និធិតែករណីដែលថ្លៃដើមទាំងនោះ បានកើតឡើង ក្នុងពេលនាំសន្និធិទាំងនោះ ទៅទីកន្លែងទុកដាក់វា និងស្របតាមលក្ខខណ្ឌនៃការទុកដាក់នោះ ។ ឧទាហរណ៍ គេអាចបញ្ចូលចំណាយមិនទាក់ទងផលិតកម្ម ឬថ្លៃដើមនៃការតុបតែងផលិត-ផល សម្រាប់អតិថិជនពិសេសណាមួយ ទៅក្នុងថ្លៃដើមសន្និធិ ។

១៦ ខាងក្រោម ជាឧទាហរណ៍នៃថ្លៃដើមដែលដកចេញពីថ្លៃដើមសន្និធិ ហើយដែលបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទ ដែលថ្លៃដើមបានកើតឡើង÷

(ក) ចំនួនទឹកប្រាក់ថ្លៃដើមមិនធម្មតានៃសម្ភារៈដែលខូចខាត ពលកម្ម និងផលិតកម្មដទៃទៀត

(ខ) ថ្លៃដើមរក្សាទុក លើកលែងតែថ្លៃដើមនោះចាំបាច់នៅក្នុងដំណើរការផលិតកម្ម មុនដំនាក់កាលផលិតក្រោយៗទៀត

(គ) ចំណាយរដ្ឋបាលដែលមិនចូលរួមក្នុងការនាំសន្និធិទៅទីកន្លែងទុកដាក់វានិងស្របតាមលក្ខខណ្ឌនៃការទុកដាក់នោះ និង

(ឃ) ថ្លៃដើមលក់។

១៧ ស្តង់ដាគណនេយ្យអន្តរជាតិលេខ ២៣ ស្តីពី*ថ្លៃដើមកម្ចី* បានកំណត់អំពីកាលទេសៈមួយចំនួនដែលថ្លៃដើមកម្ចីត្រូវបានបញ្ចូលនៅក្នុងថ្លៃដើមសន្និធិ ។

១៨ អង្គភាពមួយ អាចទិញសន្និធិតាមលក្ខខណ្ឌពន្យានៃការបង់ប្រាក់ ។ នៅពេលដែលកិច្ចសន្យាមានធាតុហិរញ្ញវត្ថុ ដូចជា ភាពខុសគ្នារវាងថ្លៃទិញតាមលក្ខខណ្ឌឥណទានធម្មតា ជាមួយនឹងចំនួនទឹកប្រាក់ ដែលបានបង់ធាតុនោះ ត្រូវបានទទួលស្គាល់ជាចំណាយលើការប្រាក់ក្នុងការិយបរិច្ឆេទធ្វើហិរញ្ញប្បទាន ។

## ថ្លៃដើមរបស់សន្និធិរបស់អ្នកផ្តល់សេវាកម្ម

១៩ ចំពោះករណី អ្នកផ្តល់សេវាដែលមានសន្និធិ អ្នកផ្តល់សេវាត្រូវវាស់វែងសន្និធិតាមថ្លៃដើមនៃការផលិតសេវាទាំងនោះ ។ ជាបឋម ថ្លៃដើមទាំងនេះ

មានថ្លៃដើមពលកម្ម និងថ្លៃដើមរបស់បុគ្គលិកដែលចូលរួមផ្ទាល់ក្នុងការផ្តល់សេវា រួមទាំងបុគ្គលិកជាអ្នកគ្រប់គ្រង និងចំណាយដទៃទៀតដែលពាក់ព័ន្ធ ។ ថ្លៃដើមពលកម្មនិងថ្លៃដើមដទៃទៀតទាក់ទិននឹងការលក់ ព្រមទាំងថ្លៃដើមបុគ្គលិករដ្ឋបាលទូទៅ មិនត្រូវបានគិតបញ្ចូល ប៉ុន្តែត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលចំណាយនោះបានកើតឡើង។ ថ្លៃដើមសន្និធិរបស់អ្នកផ្តល់សេវា មិនបញ្ចូលនៅក្នុងកម្រិតនៃប្រាក់ចំណេញ ឬចំណាយដែលមិនពាក់ព័ន្ធដែលតែងតែកំណត់ថាជាកត្តានៃថ្លៃដែលធ្វើឡើងដោយអ្នកផ្តល់សេវានោះទេ ។

## ថ្លៃដើមនៃកសិផលដែលបានប្រមូលពីទ្រព្យសកម្មជីវសាស្ត្រ

២០ ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិលេខ ៤១ ស្តីពី *កសិកម្ម* សន្និធិដែលរួមមានកសិផល ដែលអង្គភាពបានប្រមូល ពីទ្រព្យសកម្មជីវសាស្ត្ររបស់ខ្លួន ត្រូវបានវាស់វែងតាមតម្លៃទីផ្សារដែលបានទទួលស្គាល់ដំបូងដកឱ្យថ្លៃដើមលក់នាពេលប្រមូលផល ។ នេះគឺជាថ្លៃដើមនៃសន្និធិនាកាលបរិច្ឆេទដែលត្រូវអនុវត្តតាមស្តង់ដានេះ ។

## បច្ចេកទេសសម្រាប់ប្រើក្នុងការវាស់វែងថ្លៃដើម

២១ បច្ចេកទេសសម្រាប់វាស់វែងថ្លៃដើមសន្និធិ ដូចជាវិធីសាស្ត្រថ្លៃដើមស្តង់ដា ឬវិធីសាស្ត្រលក់រាយ អាចត្រូវបានប្រើប្រាស់យ៉ាងសមរម្យ ប្រសិនបើលទ្ធផល ប្រហាក់ប្រហែលថ្លៃដើម។ ថ្លៃដើមស្តង់ដា គិតអំពីកម្រិតធម្មតានៃសម្ភារៈ និងឧបករណ៍ ពលកម្ម ប្រសិទ្ធភាព និងការប្រើប្រាស់

សមត្ថភាព ។ ប្រសិនបើមានការចាំបាច់ ជាធម្មតាគេពិនិត្យឡើងវិញ និងកែសម្រួលឡើងវិញតាមលក្ខខណ្ឌជាក់ស្តែងដែលបានកើតឡើង ។

២២ វិធីសាស្ត្រលក់រាយ តែងតែត្រូវបានប្រើប្រាស់ក្នុងឧស្សាហកម្មលក់រាយសម្រាប់វាស់វែងសន្និធិ លើធាតុមួយចំនួនដែលមានការប្រែប្រួលលឿននៅក្នុងគម្លាតប្រហាក់ប្រហែលដែលការនេះគេមិនអាចប្រើវិធីសាស្ត្រថ្លៃដើមដទៃទៀតបាន ។ ថ្លៃដើមសន្និធិ ត្រូវបានកំណត់ដោយការកាត់បន្ថយតម្លៃលក់របស់សន្និធិតាមគម្លាតសរុបសមាមាត្រដែលសមហេតុផល ។ ចំនួនភាគរយដែលប្រើប្រាស់ ត្រូវពិចារណាអំពីសន្និធិដែលបានកំណត់តម្លៃទាបក្រោមថ្លៃលក់ដំបូងរបស់វា ។ ចំនួនភាគរយជាមធ្យមសម្រាប់ការលក់តាមផ្នែកតែងតែត្រូវបានប្រើប្រាស់ ។

**រូបមន្តថ្លៃដើម**

**២៣ ថ្លៃដើមសន្និធិនៃធាតុនានាដែលមិនអាចដោះដូរទៅវិញទៅមកបាន និងនៃសេវាឬទំនិញដែលបានផលិត និងបានបំបែកដោយឡែកតាមគម្រោងពិសេសនានា ត្រូវបានធ្វើឡើងដោយប្រើប្រាស់ការកំណត់ជាពិសេសលើថ្លៃដើមនីមួយៗរបស់វា ។**

២៤ ការកំណត់ជាពិសេសលើថ្លៃដើមមានន័យថា ថ្លៃដើមពិសេសត្រូវបានធ្វើឡើងចំពោះ ធាតុណាមួយនៃសន្និធិជាកំណត់ ។ នេះគឺជាប្រព្រឹត្តិកម្មដ៏សមរម្យសម្រាប់ធាតុនានា ដែលបានបំបែកទៅតាមគម្រោងដោយឡែកដោយមិនគិតថាតើវាត្រូវបានទិញឬផលិតនោះទេ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការកំណត់ថ្លៃដើមជាពិសេសនេះ អាចមិនសមរម្យនៅពេលដែលមានធាតុជាច្រើននៃ សន្និធិមិនអាចដោះដូរ ទៅវិញទៅមកបានជា

ធម្មតា ។ ក្នុងករណីនេះ វិធិសាស្ត្រនៃការជ្រើសរើសធាតុទាំងនោះនៅក្នុងសន្និធិ អាចត្រូវបានប្រើប្រាស់ដើម្បីទទួលបាននូវឥទ្ធិពលដែលកំណត់ជាមុនលើចំណេញខាត។

២៥ **លើកលែងតែសន្និធិដែលកំណត់នៅក្នុងកថាខ័ណ្ឌ ២៣ ថ្លៃដើមសន្និធិត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រចូលមុន-ចេញមុន ឬរូបមន្តថ្លៃដើមមធ្យមទម្ងន់ ។ អង្គភាពត្រូវប្រើប្រាស់ រូបមន្តថ្លៃដើមដូចគ្នាសម្រាប់គ្រប់សន្និធិដែលមានលក្ខណៈនិងប្រើប្រាស់ ដូចគ្នាចំពោះអង្គភាព។ សម្រាប់សន្និធិដែលមានលក្ខណៈឬការប្រើប្រាស់ខុសគ្នា រូបមន្តថ្លៃដើមខុសគ្នា អាចត្រូវបានកែតម្រូវ ។**

២៦ ឧទាហរណ៍ សន្និធិដែលបានប្រើនៅក្នុងផ្នែកនៃប្រតិបត្តិការមួយ អាចយកទៅប្រើក្នុងអង្គភាពខុសពីសន្និធិប្រភេទដូចគ្នា ដែលប្រើក្នុងផ្នែកប្រតិបត្តិការដទៃទៀត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ភាពខុសគ្នាតាមតំបន់ភូមិសាស្ត្ររបស់សន្និធិ (ឬក្នុងវិធានពន្ធដារពាក់ព័ន្ធ) គឺមិនគ្រប់គ្រាន់សម្រាប់ធ្វើនិយ័តកម្មការប្រើប្រាស់រូបមន្តថ្លៃដើមខុសគ្នានោះទេ ។

២៧ រូបមន្តចូលមុន-ចេញមុន សន្មត់ថាធាតុនានានៃសន្និធិដែលបានទិញ ឬផលិតមុន ត្រូវបានលក់មុន ហើយជាលទ្ធផល ធាតុនានាដែលនៅសេសសល់នៅក្នុងសន្និធិនាចុងការិយបរិច្ឆេទ គឺជាធាតុដែលបានទិញ ឬផលិតថ្មីៗបំផុត ។ តាមរូបមន្តថ្លៃដើមមធ្យម ថ្លៃដើមនៃធាតុនីមួយៗ ត្រូវបានកំណត់ពី មធ្យមទំងន់នៃថ្លៃដើមរបស់ធាតុស្រដៀងគ្នានាដើមការិយ-បរិច្ឆេទ និងថ្លៃដើមនៃធាតុស្រដៀងគ្នានានាដែលបានទិញ ឬផលិតក្នុងកំឡុងការិយបរិច្ឆេទ ។ មធ្យមភាគ អាចត្រូវបានគណនា ដោយឈរលើមូលដ្ឋានតាមដំណាក់កាល អាស្រ័យលើស្ថានភាពរបស់អង្គភាព ។

## តម្លៃសុទ្ធគួរឱ្យទុកចិត្តបាន

២៨ ថ្លៃដើមនៃសន្និធិ អាចមិនទទួលបានមកវិញ ប្រសិនបើសន្និធិទាំងនោះត្រូវបានខូចខាត ប្រសិនបើវាក្លាយជាឥតបានការទាំងស្រុងឬមួយផ្នែក ឬប្រសិនបើថ្លៃលក់របស់វាត្រូវបានបដិសេធ ។ ថ្លៃដើមនៃសន្និធិ អាចមិនទទួលបានមកវិញផងដែរ ប្រសិនបើថ្លៃដើមប៉ាន់ស្មានពេញលេញ ឬថ្លៃដើមប៉ាន់ស្មាន ដែលបានកើតឡើងសម្រាប់ការលក់បានកើនឡើង ។ ការអនុវត្តការកត់ត្រាសន្និធិចូលទាបជាងថ្លៃដើម តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន មានសង្គតិភាពជាមួយទស្សនៃទ្រព្យសកម្ម ត្រូវបានរក្សាទុកលើសពីចំនួនដែលគេរំពឹងទុកថានឹងទទួលបានមកវិញពីការលក់ ឬការប្រើប្រាស់វា ។

២៩ សន្និធិជាធម្មតាត្រូវបានកត់ត្រាចូលនូវ តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបានតាមធាតុនីមួយៗ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងកាលទេសៈខ្លះ វាអាចស័ក្តសមជាមួយនឹងក្រុមប្រហាក់ប្រហែល ឬជាមួយនឹងធាតុពាក់ព័ន្ធ ។ វាអាចជាករណីដែលធាតុនានានៃសន្និធិទាក់ទិននឹងបណ្តាញផលិត-ផលដូចគ្នា ដែលមានគោលបំណងប្រហាក់ប្រហែលគ្នា ឬការប្រើប្រាស់ចុងក្រោយប្រហាក់ប្រហែលគ្នា ត្រូវបានផលិតនិងដាក់លក់នៅក្នុងតំបន់ភូមិសាស្ត្រដូចគ្នា ហើយមិនអាចត្រូវបានវាយតម្លៃដាច់ដោយឡែកពីធាតុដទៃទៀតនៅក្នុងបណ្តាញផលិតផលនោះ ។ វាមិនត្រឹមត្រូវទាល់តែសោះចំពោះការកត់ត្រាសន្និធិ ដោយផ្អែកលើមូលដ្ឋាននៃការចាត់ថ្នាក់សន្និធិដូចជាផលិតផលសម្រេច ឬគ្រប់សន្និធិទាំងអស់នៅ ក្នុងផ្នែកនៃប្រតិបត្តិ-ការដោយឡែក ។ អ្នកផ្តល់សេវាជាទូទៅ បូកយោងថ្លៃដើម ចំពោះ

សេវាកម្មនីមួយៗ ដែលបានគិតលុយថ្លៃលក់ដាច់ដោយឡែក ។ ដូចនេះ សេវាកម្មនីមួយៗនេះ ត្រូវចាត់ទុកជាធាតុដាច់ដោយឡែក ។

៣០ ការប៉ាន់ស្មានលើតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ត្រូវបានផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលគួរឱ្យទុកចិត្តបានបំផុតដែលអាចមាននាពេលធ្វើការប៉ាន់ស្មានលើចំនួនទឹកប្រាក់ ដែលសន្និធិត្រូវបានរំពឹងទុកថានឹងទទួលបាន ។ ការប៉ាន់ស្មានទាំងនេះ ត្រូវបានយកមកពិចារណាលើការឡើងចុះនៃថ្លៃ ឬថ្លៃដើម ដែលទាក់ទងផ្ទាល់ជាមួយព្រឹត្តការណ៍ដែលកើតឡើងបន្ទាប់ពីចុងការិយបរិច្ឆេទ ដែលព្រឹត្តិការណ៍ទាំងនោះបញ្ជាក់អំពីលក្ខខណ្ឌ ដែលកើតមាននៅចុងការិយបរិច្ឆេទ ។

៣១ ការប៉ាន់ស្មានលើតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ក៏ត្រូវយកមកពិចារណាផងដែរអំពីគោលបំណងនៃការរក្សាទុកសន្និធិ ។ ឧទាហរណ៍ តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តនៃបរិមាណរបស់សន្និធិដែលមាន បំពេញបានតាមការលក់របស់ក្រុមហ៊ុន ឬកិច្ចសន្យាផ្តល់សេវាកម្មរបស់ក្រុមហ៊ុន គឺផ្អែកលើកិច្ច-សន្យាថ្លៃ ។ ប្រសិនបើកិច្ចសន្យាលក់ មានតិចជាងបរិមាណសន្និធិដែលមានតម្លៃសុទ្ធ ដែលគួរឱ្យទុកចិត្តនៃអ្វីដែលលើស ត្រូវបានផ្អែកលើមូលដ្ឋាននៃថ្លៃលក់ទូទៅ។ សំវិធានធន អាចកើតចេញពីកិច្ចសន្យាលក់របស់ក្រុមហ៊ុនលើបរិមាណសន្និធិលើសដែលមាន ឬកើតពីកិច្ចសន្យាទិញរបស់ក្រុមហ៊ុន។ សំវិធានធនបែបនេះ ត្រូវបានដោះស្រាយដោយស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៧ ស្តីពី *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ*។

៣២ សម្ភារៈ ឬគ្រឿងផ្គត់ផ្គង់ដទៃទៀត ដែលទុកសម្រាប់ប្រើនៅក្នុងការផលិតសន្និធិ មិនត្រូវបានកត់ត្រាចូលក្រោមថ្លៃដើម ប្រសិនបើផលិតផលសម្រេច

ដែលគេបានលាយបញ្ចូលគ្នា ត្រូវបានរំពឹងថាលក់តាម ឬលើសថ្លៃដើម ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលការធ្លាក់ចុះថ្លៃនៃសម្ភារៈបង្ហាញថាថ្លៃដើមរបស់ផលិតផលសម្រេចលើសពីថ្លៃដើមសុទ្ធ ដែលគួរឱ្យទុកចិត្តបាន នោះសម្ភារៈទាំងនោះត្រូវកត់ត្រានូវ ថ្លៃដើមសុទ្ធដែលគួរឱ្យទុកចិត្តបាន ។ ក្នុងកាលទេសៈបែបនេះ ថ្លៃដើមជំនួសរបស់សម្ភារៈ គឺជាខ្នាតដែលអាចធ្វើបាន ដែលល្អបំផុតនៃថ្លៃដើមសុទ្ធ ដែលគួរឱ្យទុកចិត្តបានរបស់សម្ភារៈនោះ ។

៣៣ ការវាយតម្លៃជាថ្មីត្រូវបានធ្វើឡើងលើតម្លៃសុទ្ធ ដែលគួរឱ្យទុកចិត្តនៅក្នុងការិយបរិច្ឆេទបន្តបន្ទាប់នីមួយ ។ នៅពេលដែលកាលទេសៈដែលពីមុនមកធ្វើឱ្យស្តុកត្រូវបានកត់ត្រា ក្រោមថ្លៃដើម ដែលមានក្នុងរយៈពេលមិនយូរ ឬនៅពេល ដែលមានភស្តុតាងច្បាស់លាស់បង្ហាញអំពីការកើនឡើងនូវតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ដោយសារតែការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច ចំនួនទឹកប្រាក់ដែលបានកត់ត្រាត្រូវបានធ្វើបញ្ច្រាសមកវិញ (ដូចជាការកត់ត្រាបញ្ច្រាស ត្រូវបានដាក់កំហិតចំពោះចំនួនទឹកប្រាក់ដែលបានកត់ត្រាពីដើមដំបូង) ដូចនេះ តម្លៃពិតគណនេយ្យ ទាបជាងថ្លៃដើម និងទាបជាងតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ។ ឧទាហរណ៍ ដោយសារតែថ្លៃលក់របស់វាបានកើនឡើង ករណីនេះ កើតមាននៅពេលដែលធាតុមួយនៃសន្និធិដែលបានកត់ត្រាតាមតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត នៅតែមានក្នុងដៃនាការិយបរិច្ឆេទបន្តបន្ទាប់ ហើយថ្លៃលក់របស់វាបានកើនឡើង ។

## ការទទួលស្គាល់ជាចំណូល

៣៤ នៅពេលដែលសន្និធិត្រូវបានលក់ចេញ តម្លៃពិតគណនេយ្យនៃសន្និធិទាំងនោះត្រូវបានទទួលស្គាល់ថាជាចំណាយមួយក្នុងការិយបរិច្ឆេទដែលចំណូលពាក់ព័ន្ធត្រូវបានទទួលស្គាល់ ។ បរិមាណនៃសន្និធិដែលបានកត់ត្រាតាមតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត និងរាល់ការបាត់បង់នៃសន្និធិត្រូវតែបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលការកត់ត្រាឬការបាត់បង់ត្រូវបានកើតឡើង ។ ចំនួនទឹកប្រាក់នៃការកត់ត្រាបញ្ច្រាសនៃសន្និធិបានកត់ត្រា ដែលកើតពីការកើនឡើងនៃតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ត្រូវទទួលស្គាល់ថាជាការកាត់ចេញពីចំនួនទឹកប្រាក់នៃសន្និធិដែលបានទទួលស្គាល់ថាជាចំណាយនាការិយបរិច្ឆេទដែលការកត់ត្រាបញ្ច្រាសបានធ្វើឡើង ។

៣៥ សន្និធិខ្លះ អាចត្រូវបានបញ្ចូលក្នុងគណនីទ្រព្យសកម្មដទៃទៀត ឧទាហរណ៍ សន្និធិដែលបានប្រើជាសមាសធាតុមួយ នៃទ្រព្យសកម្មដែលបានបង្កើតឡើងដោយខ្លួនឯង រោងចក្រ ឬសម្ភារៈ ។ សន្និធិនានាដែលបានបញ្ចូលក្នុងទ្រព្យសកម្មដទៃទៀត តាមមធ្យោបាយនេះ ត្រូវបានទទួលស្គាល់ថាជាចំណាយមួយក្នុងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ ។

## ការលាតត្រដាងព័ត៌មាន

៣៦ របាយការណ៍ហិរញ្ញវត្ថុ ត្រូវលាតត្រដាងព័ត៌មាន÷

(ក) គោលនយោបាយគណនេយ្យដែលបានអនុម័តដើម្បីវាស់វែងសន្និធិ រួមទាំងរូបមន្តថ្លៃដើមដែលបានប្រើប្រាស់

(ខ) តម្លៃពិតគណនេយ្យសរុបរបស់សន្និធិ និងតម្លៃពិតគណនេយ្យក្នុងការធ្វើចំណាត់ថ្នាក់ សមស្របជាមួយអង្គភាព

(គ) តម្លៃពិតគណនេយ្យរបស់សន្និធិដែលបានធ្វើឡើងតាមតម្លៃទីផ្សារដកឱ្យថ្លៃដើមលក់

(ឃ) បរិមាណនៃសន្និធិដែលត្រូវបានទទួលស្គាល់ថាជាចំណាយនៅក្នុងការិយបរិច្ឆេទ

(ង) បរិមាណនៃការកត់ត្រាសន្និធិដែលបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទ ស្របតាមកថាខ័ណ្ឌ ៣៤

(ច) បរិមាណនៃការកត់ត្រាបញ្រ្ចាសពីកំណត់ត្រាមុនដែលត្រូវបានទទួលស្គាល់ថាជាការកាត់ចេញពីបរិមាណសន្និធិ ដែលបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទ ស្របតាមកថាខ័ណ្ឌ ៣៤

(ឆ) កាលទេសៈ ឬព្រឹត្តិការណ៍ដែលនាំឱ្យមានការកត់ត្រាបញ្រ្ចាសពីកំណត់ត្រាសន្និធិស្របតាមកថាខ័ណ្ឌ ៣៤ និង

(ជ) តម្លៃពិតគណនេយ្យរបស់សន្និធិដែលជាប់សន្យាជាការធានាចំពោះបំណុល ។

៣៧ ព័ត៌មានអំពីតម្លៃពិតគណនេយ្យ ដែលមាននៅក្នុង ចំណាត់ថ្នាក់ខុសគ្នានៃសន្និធិ និងទំហំនៃការប្រែប្រួលលើទ្រព្យសកម្មទាំងនេះ មានប្រយោជន៍ចំពោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ។ ចំណាត់ថ្នាក់រួម នៃសន្និធិមានដូចជា ម៉ាស៊ីន ឧបករណ៍ផលិតកម្ម សម្ភារៈ ផលិតផលមិនទាន់សម្រេច និងផលិតផលសម្រេច ។ សន្និធិរបស់អ្នកផ្តល់សេវាកម្ម អាចត្រូវបានទុកជាផលិតផលមិនទាន់សម្រេច ។

៣៨ ចំនួនសន្និធិ ដែលត្រូវបានទទួលស្គាល់ថាជាចំណាយមួយនៅក្នុងការិយ-បរិច្ឆេទ ដែលតែងតែសំដៅដល់ថ្លៃដើមលក់ រួមមានថ្លៃដើមដែលពីមុនមកត្រូវបានបញ្ចូលនៅក្នុងការវាស់វែងសន្និធិដែលឥឡូវបានលក់ ហើយមិនបានបញ្ចូលជាចំណាយក្នុងផលិតកម្មនិងមិនបានបញ្ចូលក្នុងចំនួនថ្លៃដើមផលិតកម្មមិនធម្មតារបស់សន្និធិ ។ ស្ថានភាពរបស់អង្គភាព អាចអនុញ្ញាតឱ្យមានការដាក់បញ្ចូលនូវចំនួនទឹកប្រាក់ដទៃទៀត ដូចជាថ្លៃដើមចែកចាយ ។

៣៩ អង្គភាពខ្លះ អនុម័តទម្រង់សម្រាប់ចំណេញ-ខាត ដែលបង្ហាញលទ្ធផលជាចំនួនទឹកប្រាក់ដែលត្រូវលាតត្រដាងព័ត៌មាន ក្រៅពីថ្លៃដើមសន្និធិដែលត្រូវបានទទួលស្គាល់ថាជាចំណាយនៅក្នុងការិយបរិច្ឆេទ ។ តាមទម្រង់នេះ អង្គភាពបង្ហាញនូវការវិភាគលើ ចំណាយដោយប្រើចំណាត់ថ្នាក់មួយផ្អែកលើមូលដ្ឋាននៃប្រភេទនៃចំណាយ ។ ក្នុងករណីនេះ អង្គភាពលាតត្រដាងព័ត៌មានអំពី ថ្លៃដើមដែលបានទទួលស្គាល់ថាជាចំណាយ សម្រាប់វត្ថុធាតុដើម និងគ្រឿងប្រើប្រាស់ ថ្លៃដើមពលកម្ម និងថ្លៃដើមដទៃទៀត ជាមួយនឹងចំនួនទឹកប្រាក់នៃការប្រែប្រួលសរុបលើសន្និធិសម្រាប់ការិយបរិច្ឆេទ ។

## កាលបរិច្ឆេទចូលជាធរមាន

៤០ អង្គភាពមួយត្រូវអនុវត្តស្តង់ដានេះ សម្រាប់ការិយបរិច្ឆេទនៃឆ្នាំដោយចាប់ផ្តើមចាប់ពីឬបន្ទាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០៥។ ការអនុវត្តមុន ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាពអនុវត្តស្តង់ដានេះសម្រាប់ការិយ-បរិច្ឆេទចាប់ផ្តើមមុនថ្ងៃទី ១ មករា ២០០៥ អង្គភាពនោះត្រូវលាតត្រដាងអំពីការណ៍នេះ ។

៤០ក (លុបចោល)

៤០ខ ស.រ.ហ.អ. ៩ ដែលបានចេញផ្សាយក្នុងខែ តុលា ឆ្នាំ ២០១០ បានវិសោធនកម្មកថាខ័ណ្ឌ ២(ខ) និងលុបចោលកថាខ័ណ្ឌ ៤០ក។ អង្គភាពត្រូវអនុវត្តវិសោធនកម្មទាំងនោះ នៅពេលដែលអង្គភាពអនុវត្តស.រ.ហ.អ. ៩ ដែលបានចេញផ្សាយក្នុងខែ តុលា ឆ្នាំ ២០១០ ។

## ការដកចេញសេចក្ដីប្រកាសដទៃទៀត

៤១ ស្តង់ដានេះ ជំនួសឱ្យស្តង់ដាអន្តរជាតិលេខ ២ ស្ដីពី*សន្និធិ* (ដែលបានកែសម្រួលក្នុងឆ្នាំ១៩៩៣)។

៤២ ស្តង់ដានេះ ជំនួសឱ្យការបកស្រាយ SIC-1 ស្ដីពី*សង្គតិភាព-រូបមន្តថ្លៃដើមខុសៗគ្នានៃសន្និធិ* ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ